ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 01 / 2017
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**សាធារណៈ / Public**

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, សហចៅក្រមស៊ើបអង្កេត**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំការអនុញ្ញាតផ្តល់ឯកសារសម្ងាត់ពីសំណុំរឿង ០០២ ដល់មេធាវីការពារក្តី មាស មុត ក្នុងសំណុំរឿង ០០៣**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំសម្ងាត់មួយ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ សុំការអនុញ្ញាតផ្តល់ឯកសារសម្ងាត់ពីសំណុំរឿង ០០២ ដល់មេធាវីការពារក្តី មាស មុត ក្នុងសំណុំរឿង ០០៣ (ឯកសារ E442/2 "សំណើសុំ")។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំជាក់លាក់ អនុលោមតាមនីតិវិធីដែលបានកំណត់នៅក្នុងដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ សុំការអនុញ្ញាតដាក់បង្ហាញឯកសារដែលលើកឡើងនៅក្នុងឧបសម្ព័ន្ធសម្ងាត់ ក (ឯកសារ E442/2.2) ដោយផ្អែកលើមូលដ្ឋានថា មេធាវីការពារក្តី មាស មុត ចាំបាច់ត្រូវចូលទៅពិនិត្យមើលសម្ភារៈទាំងនេះ ដើម្បីឆ្លើយតបទៅនឹងសំណើរបស់ ក.ស.ព សុំដាក់ឯកសារទៅក្នុងសំណុំរឿង ០០៣ (ឯកសារ E442/2 កថាខណ្ឌ ១-៣)។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើ

សុំការអនុញ្ញាតនេះជាបន្ទាន់ ដោយសារតែការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ នឹងត្រូវបិទបញ្ចប់នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ហើយបន្ទាប់មក ភាគីមានរយៈពេល ៣០ ថ្ងៃ ក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ដែលរួមទាំង ការបញ្ចូលសម្ភារៈនានាទៅក្នុងសំណុំរឿង ០០៣ ផងដែរ។ គ្មានភាគីណាមួយដាក់សារណាឆ្លើយតបទៅនឹងសំណើនេះទេ។

២. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា អង្គជំនុំជម្រះធ្លាប់បានយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិរួចមកហើយ ក្នុងការផ្តល់ការអនុញ្ញាតដល់ក្រុមមេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ និង ០០៤ ឱ្យចូលទៅពិនិត្យមើលឯកសារមួយចំនួនដែលត្រូវបានចាត់ទុកថាពាក់ព័ន្ធទៅនឹងការស្វែងរកការពិតនៅក្នុងសំណុំរឿងទាំងនោះ និងអនុញ្ញាតឱ្យបញ្ជូនឯកសារទាំងនោះទៅក្នុងសំណុំរឿងដែលពាក់ព័ន្ធ (ឯកសារ E442/1 កថាខណ្ឌ ២-៣)។ បន្ទាប់ពីបានពិនិត្យបញ្ជីឯកសារនៅក្នុងឧបសម្ព័ន្ធ ក អង្គជំនុំជម្រះមិនជំទាស់ទៅនឹងការផ្តល់ឯកសារសម្ងាត់ទាំងនេះ ពីសំណុំរឿង ០០២ ដល់មេធាវីការពារក្តី មាស មុត នោះទេ។

៣. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំនេះ និងអនុញ្ញាតឱ្យ ក.ស.ព ដោយមានការសម្របសម្រួលពីផ្នែកគ្រប់គ្រងតុលាការ ក្នុងការបញ្ជូនឯកសារអេឡិចត្រូនិក ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធសម្ងាត់ ក នៃឯកសារ E442/2.2 ទៅមេធាវីការពារក្តី មាស មុត ក្នុងសំណុំរឿង ០០៣។ អង្គជំនុំជម្រះរម្លឹកថា ឯកសារទាំងនេះ គឺជាឯកសារសម្ងាត់ ដូចនេះត្រូវរក្សានូវភាពសម្ងាត់របស់វា។

៤. អនុស្សរណៈនេះជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E442/2។